https://www.vodkhmer.news/2020/05/14/factory-worker-meanchey-district-guard-factory-after-suspect-runs-away/ Go SEP MAR APR
16 captures 22
20 May 2020 - 22 Mar 2024 2023 2024 2025 About this capture



# កម្មកររោងចក្រមួយនៅខណ្ឌមានជ័យដេកយាមមុខរោងចក្រ ក្រោយសង្ស័យថៅកែរត់ចោលមិនបើកប្រាក់ឈ្នួល

ព័ត៌មានជាតិ ការងារ សេដ្ឋកិច្ច -

លោក យុត សុគន្ធ | ១៤ ឧសភា ២០២០ ម៉ោង ១៨:១៧



កម្មករ-កម្មការិនីបម្រើការងារនៅរោងចក្រកាត់ដេរសម្លៀកបំពាក់ ឡាក់ឃី លី សាន់ឡុង (Lucky Ly Sunn Long Garment Co.Ltd) ស្ថិតក្នុងខណ្ឌមានជ័យ រាជធានីភ្នំពេញ ទៅតវ៉ា និងពិនិត្យនៅរោងចក្រ ក្រោយពីសង្ស័យថាមានករណីដឹកសម្ភារចេញពីរោងចក្រ ថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២០។ (CCAWDU ស៊ីខៅឌូ)

កម្មករ-កម្មការិនីបម្រើការងារនៅរោងចក្រកាត់ដេរសម្លៀកបំពាក់ ឡាក់ឃី លី សាន់ឡុង (Lucky Ly Sunn Long Garment Co.Ltd) ស្ថិតក្នុងខណ្ឌមានជ័យ រាជធានីភ្នំពេញ បាននាំគ្នាដេកយាមមុខរោងចក្ររយៈពេល ៤ថ្ងៃហើយ ក្រោយសង្ស័យថា ថៅកែរត់ចោលដោយមិនបានបើកប្រាក់ឈ្នួល និងទូទាត់អត្ថប្រយោជន៍ជូនពួកគេ។

កម្មការិនីមានផ្ទៃពោះ ៨ខែ ដែលកំពុងយាមមុខរោងចក្រ ដោយបារម្ភខ្លាចមានការដឹកសម្ភារបន្ថែមទៀតនោះ អ្នកស្រី មិត វ៉ាន់នៀន រៀបរាប់ប្រាប់វីអូឌីថា ដំបូងឡើយ ថៅកែរោងចក្រ ឡាក់ឃី លី សាន់ឡុង បានព្យួរការងារកម្មករ ១ខែ គឺចាប់ពីថ្ងៃទី៤ ខែមេសា ដល់ថ្ងៃទី៤ ខែឧសភា ដោយតម្រូវឱ្យកម្មករទទួលប្រាក់ឈ្នួល ៥០ភាគរយនៃប្រាក់ឈ្នួលគោល។

កម្មករ ២ខែបន្ថែមទៀត ខណៈប្រាក់ឈ្នួលអំឡុងពេលព្យួរការងារពីខែមុន មិនទាន់បានបើកជូនកម្មករនៅឡើយ។

អ្នកស្រី មិត វ៉ាន់នៀន អះអាងថា អំឡុងពេលកម្មករឈប់សម្រាកនៅផ្ទះពេលព្យួរការងារនោះ គឺថៅកែបានលួចដឹកសម្ភារល្អៗចេញពីរោងចក្រអស់ និងបិទទ្វាររោងចក្រ ដោយមិនបានជូនដំណឹង និងដោះស្រាយសំណងជូនកម្មករត្រឹមត្រូវឡើយ។




*កម្មការិនីមានផ្ទៃពោះ ៨ខែ អ្នកស្រី មិត វ៉ាន់នៀន រៀបរាប់ប្រាប់អ្នកព័ត៌មានវីអូឌី ពីបញ្ហាប្រឈមក្រោយពេលថៅកែព្យួរការងារ និងមិនបានដោះស្រាយសំណងជូនត្រឹមត្រូវតាមផ្លូវច្បាប់ ព្រឹកថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០២០។ (ហ៊ី ឆាយ)*

> អ្នកស្រីបន្ថែមថា៖ «ខ្ញុំអំពាវនាវដល់ប្រមុខរដ្ឋាភិបាលជួយអន្តរាគមន៍ដោះស្រាយដល់ពួកខ្ញុំឱ្យបានឆាប់។ ជាពិសេសស្ត្រីមានផ្ទៃពោះ ពួកគាត់កំពុងជួបបញ្ហាច្រើនណាស់ ព្រោះពេលរោងចក្របិទទ្វារ គឺគាត់មិនទទួលបានសំណង ឬលុយអ្វីពីរោងចក្រទេ។ ពួកគាត់រំពឹងលើរឿងហ្នឹងហើយ ដើម្បីសម្រាលកូន។ ដល់ពេលថៅកែរត់ចោលអ៊ីចឹង ពួកគាត់អត់មានលុយទេ»។

កម្មការិនីដែលអះអាងថា បម្រើការងារនៅរោងចក្រ ឡាក់ឃី លី សាន់ទ្បុង អស់រយៈពេល ៤ឆ្នាំ អ្នកស្រី គង់ និច និយាយថា ករណីថៅកែបិទទ្វាររោងចក្រ និងមិនដោះស្រាយសំណងជូនកម្មករនេះ បានធ្វើឱ្យគ្រួសារអ្នកស្រីប្រឈមជួបការលំបាកក្នុងការចំណាយប្រចាំថ្ងៃ និងគ្មានលុយសងកម្ចីធនាគារឡើយ។

កម្មការិនីផ្នែកដេររូបនេះ ឱ្យដឹងថា មួយខែ អ្នកស្រីត្រូវបង់សងធនាគារប្រហែល ១៥០ដុល្លារ និងត្រូវចំណាយផ្សេងៗទៀត ដូចជា ថ្លៃបន្ទប់ជួល ទឹកភ្លើង ជាដើម។

> អ្នកស្រីបន្ថែមថា៖ «កម្មករយើងកំពុងខ្វះលុយបង់ផ្ទះជួល ទឹកភ្លើង បង់ធនាគារ។ ឥលូវពិបាកខ្លាំងណាស់ ព្រោះផ្ទះជួលលើសមួយថ្ងៃ គេយកថែម ៣ម៉ឺនរៀលទៀត ខាងខ្ញុំនៅហ្នឹង។ ឥលូវខ្ញុំរើចេញហើយ ដោយសារអត់លុយបង់ឱ្យគេ»។

បើតាមអ្នកស្រី គង់ និច បច្ចុប្បន្ន សម្ភារនៅរោងចក្រ ឡាក់ឃី លី សាន់ទ្បុង នៅសល់បន្តិចបន្តួចប៉ុណ្ណោះ និងជាសម្ភារចាស់ៗទៀត ដោយសារថៅកែលួចដឹកចេញអំឡុងពេលព្យួរការងារ ហើយអ្នកស្រីមិនរំពឹងថា សម្ភារដែលនៅសេសសល់នោះ អាចលក់យកមកដោះស្រាយសំណងជូនកម្មករបានសមរម្យនោះទេ។

វីអូឌីមិនអាចរកការឆ្លើយតបពីភាគីរោងចក្របានទេចំពោះករណីនេះ។

មន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ លោក ផ៉យ សុវណ្ណា ដែលចុះសម្របសម្រួលដោះស្រាយវិវាទការងារនៅរោងចក្រ ឡាក់ឃី លី សាន់ទ្បុង មានប្រសាសន៍ថា រហូតមកដល់ពេលនេះ ក្រសួងការងារមិនទាន់សម្រេចថាយ៉ាងណានៅឡើយទេ ដោយរង់ចាំការសម្រេចពីក្រុមកម្មករ។ លោកថា ក្នុងដំណើរការដោះស្រាយនោះ គឺកម្មករមួយក្រុមទាមទារដោះស្រាយតាមប្រព័ន្ធតុលាការ និងមួយក្រុម

ទៀតស្នើដោះស្រាយក្រៅប្រព័ន្ធតុលាការ។

ចំពោះករណីថា ថៅកែបិទទ្វាររោងចក្រ និងរត់ចោលនោះ គឺមន្ត្រីការងាររូបនេះសុំមិនឆ្លើយទេ ដោយលោកថា ក្រសួងការងារទុកឱកាសវាទឱ្យថៅកែនោះពិចារណាចេញមុខមកដោះស្រាយសិន។

> លោកបន្ថែមថា៖ «យើងចង់ធ្វើយ៉ាងណាឱ្យពួកគាត់មានការឯកភាពរួមមួយ។ ប្រសិនបើពួកគាត់ចង់ទៅប្រព័ន្ធតុលាការ យើងនឹងរៀបចំឯកសារ របាយការណ៍ដាក់ទៅឯកឧត្តមរដ្ឋមន្ត្រីដើម្បីឱ្យលោកពិនិត្យ ហើយរុញទៅដោះស្រាយតាមនីតិវិធីច្បាប់។ ប៉ុន្តែ បើពួកគាត់សម្រេចដោះស្រាយក្រៅប្រព័ន្ធតុលាការ អ៊ីចឹង គាត់ធ្វើលិខិតជូនដំណឹងទៅថៅកែ ទៅភាគីពាក់ព័ន្ធទាំងអស់ ដើម្បីចូលមកដោះស្រាយ ដោយទុកឱកាសវាទយ៉ាងហោចណាស់ ៧ថ្ងៃដែរ។ បើក្នុងរយៈពេលថ្ងៃហ្នឹង អត់មានភាគីពាក់ព័ន្ធណាចូលមកដោះស្រាយ អ៊ីចឹងបងប្អូនកម្មករគាត់មានសិទ្ធិលក់សម្ភារឡាយឡុង ដើម្បីយកលុយទូទាត់ប្រាក់ឈ្នួលពួកគាត់»។

មន្ត្រីផ្នែកច្បាប់ និងដោះស្រាយវិវាទនៃសម្ព័ន្ធសហជីពស៊ីខៅខ្ម លោក ស៊ាង យ៉ូត មានប្រសាសន៍ថា តាមផ្លូវច្បាប់ នៅពេលរោងចក្របិទ ឬបញ្ឈប់កម្មករពីការងារ គឺការដោះស្រាយសំណងជូនកម្មករពឹងផ្អែកទៅលើកិច្ចសន្យាការងារ។

លោក ស៊ាង យ៉ូត បន្តថា ក្នុងករណីកម្មករប្រើប្រាស់កិច្ចសន្យាមិនកំណត់ ថៅកែត្រូវទូទាត់សំណងជូនកម្មករចំនួន ៥ចំណុច មានប្រាក់ខែចុងក្រោយ ប្រាក់ជូនដំណឹង ប្រាក់អតីតភាពការងារ ប្រាក់ជំងឺចិត្ត និងប្រាក់ដំណាច់ឆ្នាំ។

ចំពោះកម្មករដែលប្រើប្រាស់កិច្ចសន្យាកំណត់វិញ លោកថា ថៅកែត្រូវទូទាត់សំណងជូនពួកគេចំនួន ៤ចំណុចមាន ប្រាក់ឈ្នួលចុងក្រោយ ប្រាក់៥ភាគរយ ប្រាក់ដំណាច់ឆ្នាំដែលនៅសល់ និងប្រាក់ជំងឺចិត្ត ក្នុងករណីកិច្ចសន្យាការងាររបស់ពួកគេនៅសល់។

លោក ស៊ាង យ៉ូត បន្ថែមទៀតថា ក្នុងករណីថៅកែរត់បាត់ គ្មានលុយទូទាត់សំណងជូនកម្មករ គឺរដ្ឋាភិបាលត្រូវស្រាវជ្រាវស្វែងរកថៅកែឱ្យមកទទួលខុសត្រូវ ឬដកលុយដែលថៅកែតម្កល់នៅក្រសួងពាណិជ្ជកម្ម ឬបញ្ចេញកញ្ចប់ថវិកាណាមួយយកមកដោះស្រាយសំណងជូនកម្មករ។

ប្រធានសម្ព័ន្ធសហជីពស៊ីខៅខ្ម លោក គង់ អាទិត្យ មានប្រសាសន៍ថា បច្ចុប្បន្ន លោកមើលឃើញរូបភាពអាក្រក់ពីររបស់ថៅកែរោងចក្រដែលកំពុងគេចវេសពីការដោះស្រាយសំណងជូនកម្មករ ក្រោមហេតុផលគ្មានអ្នកបញ្ជាទិញដោយសារបញ្ហាជំងឺកូវីដ១៩។

ប្រធានសម្ព័ន្ធសហជីពរូបនេះ បន្តថា ថៅកែរោងចក្រមួយចំនួន បានយកពេលវេលាអំឡុងព្យួរការងារ បិទទ្វាររោងចក្រ ហើយរត់ចោលដោយមិនបានដោះស្រាយសំណងជូនកម្មករត្រឹមត្រូវ និងថៅកែមួយចំនួនទៀត បានយកចន្លោះពេលព្យួរការងារនោះ ទៅបញ្ចប់កិច្ចសន្យាការងារកម្មករ ដោយមិនបានដោះស្រាយសំណងទៅតាមផ្លូវច្បាប់ឡើយ។

លោក គង់ អាទិត្យ បានស្នើឱ្យក្រសួងការងារចុះស្រាវជ្រាវ ឬធ្វើអធិការកិច្ចចំពោះរោងចក្រទាំងអស់នោះ ដើម្បីបង្ហាញភាពត្រឹមត្រូវពីមូលហេតុនៃការបិទអាជីវកម្មរបស់ខ្លួន។

> លោកបន្ថែមថា៖ «ក្រសួងត្រូវធ្វើអធិការកិច្ចរកឱ្យឃើញថា រោងចក្រហ្នឹងបិទមែន ឱ្យវាប្រាកដជាបិទមែន ហើយមានភស្តុតាងអី? ហើយគោរពទៅតាមមាត្រាណានៃច្បាប់ការងារ ដោយមានការធ្វើអធិការកិច្ចឱ្យបានត្រឹមត្រូវ។ យើងមិនអាចធ្វើដូចរាល់ថ្ងៃហ្នឹងទេ។ ឧទាហរណ៍ថា ក្រុមហ៊ុនរំសាយកម្មករ រំសាយដោយសារមូលហេតុអី? ក្រុមហ៊ុននោះត្រូវធ្វើលិខិតដាក់ទៅក្រសួងឱ្យបានត្រឹមត្រូវ ដើម្បីយើងធ្វើនីតិវិធីបានត្រឹមត្រូវទាំងអស់គ្នា»។

បើតាមលោក គង់ អាទិត្យ មានរោងចក្រចំនួន ៦ហើយដែលបានបិទទ្វារខុសនីតិវិធីច្បាប់ និងដោះស្រាយជូនកម្មករមិនបានត្រឹមត្រូវនោះ។

វីអូឌីបានសុំការបញ្ជាក់ពីអ្នកនាំពាក្យក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ លោក ហេង សួរ តាមប្រព័ន្ធ Telegram ដែរ អំពីចំនួនរោងចក្រដែលបានបិទ ប៉ុន្តែ លោកមិនឆ្លើយតប៕

---

**រក្សាសិទ្ធិគ្រប់យ៉ាងដោយ ស៊ីស៊ីអាយអឹម**

សូមបញ្ជាក់ថា គ្មានផ្នែកណាមួយនៃអត្ថបទ រូបភាព សំឡេង និងវីដេអូទាំងនេះ អាចត្រូវបានផលិតឡើងវិញក្នុងការបោះពុម្ពផ្សាយ ផ្សព្វផ្សាយ ការសរសេរឡើងវិញ ឬ ការចែកចាយឡើងវិញ ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរឡើយ។
ស៊ីស៊ីអាយអឹម មិនទទួលខុសត្រូវចំពោះការលួចចម្លងនិងចុះផ្សាយបន្តណាមួយ ដែលខុស នាំឲ្យយល់ខុស បន្លំ ក្លែងបន្លំ តាមគ្រប់ទម្រង់និងគ្រប់មធ្យោបាយ។ ជនប្រព្រឹត្តិ និងអ្នកផ្សំគំនិត ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់កម្ពុជា និងច្បាប់នានាដែលពាក់ព័ន្ធ។

## អត្ថបទទាក់ទង

[សូមផ្តល់មតិយោបល់លើអត្ថបទនេះ]

នាម និងគោត្តម *

សូមវាយបញ្ចូលឈ្មោះរបស់អ្នក

អ៊ីម៉ែល *

សូមវាយអាសយដ្ឋានអ៊ីម៉ែលរបស់អ្នក...

លេខទូរសព្ទ (មិនចាំបាច់)

បើសិនជាអ្នកចង់ឱ្យខាងក្រុមការងារ វិទ្យុ ទាក់ទងទៅអ្នក សូមទម្លាក់លេខទូរសព្ទ ...

មតិយោបល់ *

សូមបញ្ចេញមតិយោបល់សម្រាប់អត្ថបទខាងលើនេះ...

Could not connect to the reCAPTCHA service. Please check your internet connection and reload to get a reCAPTCHA challenge.

ចុចបញ្ជូន



លោក ហ៊ុន ម៉ាណែត បដិសេធមិនបានចុះហត្ថលេខាជំនួសនាយករដ្ឋមន្ត្រី រឿងផ្តល់ជំនួយដល់ប្រទេសតួកគីនោះទេ

១២ កុម្ភៈ ២០២៣ ម៉ោង ១៨:១២

ធនាគារជាតិព្រមានវិធានការច្បាប់លើម្ចាស់គ្រឹះស្ថានឥណទានទទួលយកអត្តសញ្ញាណបណ្ណឬសៀវភៅគ្រួសារពីកូនបំណុល

១២ កុម្ភៈ ២០២៣ ម៉ោង ១៣:១៤

ក្រសួងការងារថា ក្រុមហ៊ុន ខេមបូ ហៃនសាំ យល់ព្រមទូទាត់ប្រាក់បំណាច់បញ្ចប់កិច្ចសន្យាការងារជូនកម្មករ

១១ កុម្ភៈ ២០២៣ ម៉ោង ១៦:១៣

អង់គ្លេសសង្ឃឹមថា ការបោះឆ្នោតជាតិខាងមុខនឹងប្រព្រឹត្តទៅដោយសេរី យុត្តិធម៌ និងគ្មានការគំរាមកំហែង

ព្រះមហាក្សត្រតែងតាំងសាស្ត្រាចារ្យផ្នែកប្រវត្តិសាស្ត្រលោក សំបូរ មាណ្ណារ៉ា ជាទីប្រឹក្សាលោក ហ៊ុន សែន

១១ កុម្ភៈ ២០២៣ ម៉ោង ១៥:៤៦

១១ កុម្ភៈ ២០២៣ ម៉ោង ១៤:៥៣




VOD

VOD គឺជាស្ថាប័នព័ត៌មានឯករាជ្យដែលផ្តល់ព័ត៌មាន ផលិតកម្មវិធីវិទ្យុ និងការផ្សព្វផ្សាយតាមរយៈគេហទំព័រអ៊ីនធើណេត។


info@vodhotnews.com

+៨៥៥ ២៣ ៧២៦ ៨៤៥ - លេខបន្ទាន់: +៨៥៥ ៩២ ៩២ ១៩ ០២ / +៨៥៥ ៦០ ៤០ ៤០ ៤០

ផ្ទះលេខ១៤A ផ្លូវ៣៩២ សង្កាត់បឹងកេងកង១ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ





ស្វែងរកព័ត៌មាន

អំពីយើង

បណ្ណាសាររូបភាព


ចុះឈ្មោះទទួលព្រឹត្តិបត្រព័ត៌មានវីអូឌី

Enter your email

Subscribe

INTUIT mailchimp